**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សហភាពសហព័ន្ធយុវជនកម្ពុជា (ស.ស.យ.ក)**
**UNION OF YOUTH FEDERATIONS OF CAMBODIA (UYFC)**
**គណៈកម្មាធិការកណ្ដាល**
លេខ...៥៥/២៥...ស.ស.យ.ក.

**សូមគោរពជូន**
**ឯកឧត្តម លោកជំទាវ ប្រធានគណៈកម្មាធិការ**
**សហភាពសហព័ន្ធយុវជនកម្ពុជា រាជធានី-ខេត្ត**

**កម្មវត្ថុ៖** អំពីសំណើសុំកិច្ចសហការពីគណៈកម្មាធិការ ស.ស.យ.ក. រាជធានី-ខេត្ត ដើម្បីជំរុញផ្សព្វផ្សាយឱ្យបងប្អូនអ្នកសេដ្ឋកិច្ចក្រៅប្រព័ន្ធចូលរួមចុះឈ្មោះតាម "ថ្នាលឌីជីថលចុះឈ្មោះអ្នកសេដ្ឋកិច្ចក្រៅប្រព័ន្ធ"

**យោង៖** - លិខិតលេខ៣៩១១.ឧវបន.គសអសក.លស ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤ របស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- ចំណារដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តមប្រធានសហភាពសហព័ន្ធយុវជនកម្ពុជា ចុះថ្ងៃទី០៤ ខែមករា ឆ្នាំ២០២៥

សេចក្ដីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមគោរពជម្រាបជូន **ឯកឧត្តម លោកជំទាវ** មេត្តាជ្រាបថា ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ បានស្នើសុំកិច្ចសហការពីសហភាពសហព័ន្ធយុវជនកម្ពុជា រាជធានី ខេត្ត ដើម្បីជំរុញផ្សព្វផ្សាយឲ្យបងប្អូនអ្នកសេដ្ឋកិច្ចក្រៅប្រព័ន្ធចូលរួមចុះឈ្មោះតាម "ថ្នាលឌីជីថលចុះឈ្មោះអ្នកសេដ្ឋកិច្ចក្រៅប្រព័ន្ធ"។ ចំពោះសំណើនេះ គណៈកម្មាធិការកណ្ដាលសហភាពសហព័ន្ធយុវជនកម្ពុជាបានឯកភាពជាគោលការណ៍ក្នុងការឲ្យសហភាពសហព័ន្ធយុវជនកម្ពុជា រាជធានី ខេត្តជួយជំរុញផ្សព្វផ្សាយបន្ត។

អាស្រ័យហេតុនេះ សូម គណៈកម្មាធិការសហភាពសហព័ន្ធយុវជនកម្ពុជា រាជធានី-ខេត្ត ចូលរួមសហការផ្សព្វផ្សាយដោយក្ដីអនុគ្រោះ។

សូម **ឯកឧត្តម លោកជំទាវ** ទទួលនូវការគោរពដ៏ស្មោះស្ម័គ្រពីខ្ញុំ។

ថ្ងៃ អង្គារ ១រោច ខែបុស្ស ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី១៤ ខែមករា ឆ្នាំ២០២៥
**លេខាធិការដ្ឋានគណៈកម្មាធិការកណ្ដាល**
**ប្រធាន**

**ឌី ហ្សានិត**

លេខ២៤ ផ្លូវ២២៨ កែង៥៥ សង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
N°24 St.228/55; Sangkat Chaktomuk; Khan Daun Penh; Phnom Penh; Kingdom of Cambodia
Tel: (855-23) 210 489; E-Mail: uyfcsecretariat@gmail.com